# ហិរិជាតក




ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីដែលនៅបច្ចន្តជនបទដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ហិរិំ តរន្តំ** ដូច្នេះជាដើម ។

រឿងរ៉ាវសូម្បីទាំងពីរ (រឿងរ៉ាវបច្ចុប្បន្ន និង អតីត) មានពិស្ដារហើយក្នុងជាតកជាទីបំផុតនៃនវមវគ្គ ក្នុងឯកកនិបាតនោះឯង ។ ចំណែកក្នុងជាតកនេះ មនុស្សមកប្រាប់ពារាណសិវាសិសេដ្ឋីថា មនុស្សទាំងឡាយរបស់បច្ចន្តវាសិសេដ្ឋីដណ្ដើមទ្រព្យសម្បត្តិ ជាអ្នកមិនជាម្ចាស់ទ្រព្យដែលជារបស់ខ្លួន ហើយរត់ទៅ ។ ពារាណសិវាសិសេដ្ឋីពោលថា ឈ្មោះថាមនុស្សមិនធ្វើកិច្ចដែលគប្បីធ្វើ ហើយមកកាន់សម្នាក់របស់ខ្លួន រមែងមិនបានការធ្វើតបចំពោះ ដូចគ្នា ដូច្នេះហើយ ក៏បានពោលទាំងឡាយនេះថា

ហិរិំ តរន្តំ វិជិគុច្ឆមានំ, តវាហមស្មិ ឥតិ ភាសមានំ;
សេយ្យានិ កម្មានិ អនាទិយន្តំ, នេសោ មមន្តិ ឥតិ នំ វិជញ្ញា។

*បណ្ឌិតគប្បីដឹងច្បាស់ នូវបុគ្គលដែលលះបង់នូវសេចក្ដីខ្មាស គួរខ្ពើមរអើម (ដោយភាពជាមិត្ត) ដែលគ្រាន់តែពោលថា ខ្ញុំ (ជាមិត្ត) របស់អ្នក តែមិនកាន់យកនូវអំពើដ៏ប្រសើរថា អ្នកនុ៎ះ មិនមែនជាមិត្ត របស់អញ ។*

យញ្ហិ កយិរា តញ្ហិ វទេ, យំ ន កយិរា ន តំ វទេ;
អករោន្តំ ភាសមានំ, បរិជានន្តិ បណ្ឌិតា។

*ពិតណាស់ បុគ្គលធ្វើនូវអំពើណា គួរនិយាយចំពោះអំពើនោះ បុគ្គលមិនធ្វើនូវអំពើណា មិនគួរនិយាយចំពោះអំពើនោះ ពួកបណ្ឌិតតែងស្គាល់ច្បាស់នូវបុគ្គល ដែលមិនធ្វើ គ្រាន់តែនិយាយ ។*

ន សោ មិត្តោ យោ សទា អប្បមត្តោ, ភេទាសង្កី រន្ធមេវានុបស្សី;
យស្មិញ្ច សេតី ឧរសីវ បុត្តោ, ស វេ មិត្តោ យោ អភេជ្ជោ បរេហិ។

*បុគ្គលណា ជាអ្នកប្រយ័ត្ន ក្នុងកាលទាំងពួង រង្កៀសក្នុងការបែកធ្លាយ (ចំពោះមិត្ត) សម្លឹងរំពៃរកទោសតែម្យ៉ាង អស់កាលជានិច្ច អ្នកនោះ មិនឈ្មោះថាមិត្តឡើយ មួយទៀត បុគ្គលណា ដែលពួកជនដទៃ បំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះ ទើបឈ្មោះថា មិត្តដោយពិត ។*

បាមោជ្ជករណំ ឋានំ, បសំសាវហនំ សុខំ;
ផលានិសំសោ ភាវេតិ, វហន្តោ បោរិសំ ធុរំ។

*កុលបុត្តអ្នកមានផលានិសង្ស កាលនាំទៅនូវធុរៈ ជារបស់បុរស រមែងចម្រើននូវហេតុជាគ្រឿងធ្វើនូវបាមោជ្ជៈ ជាគ្រឿងនាំមកនូវសេចក្ដីសរសើរ ជាសុខ ។*

**បវិវេករសំ បិត្វា, រសំ ឧបសមស្ស ច;**
**និទ្ទរោ ហោតិ និប្បាបោ, ធម្មប្បីតិរសំ បិវំ។**

*បុគ្គលផឹកនូវរសនៃវិវេកធម៌ផង នូវរសនៃសេចក្ដីស្ងប់រម្ងាប់ផង ផឹកនូវរសនៃធម្មបីតិផង ទើបជាអ្នកមិនមានកង្វល់ មិនមានបាប ។*

*បណ្ដាបទទាំងនោះ បទថា* **ហិរឹ តរន្តំ** *សេចក្ដីថា កន្លងបង់នូវសេចក្ដីខ្មាស់ ។ បទថា* **វិជិគុច្ឆមានំ** *សេចក្ដីថា ខ្ពើមរអើមដោយភាពជាមិត្ត ។ បទថា* **តវាហមស្មិ** *សេចក្ដីថា គ្រាន់តែពោលដោយប្រមាណត្រឹមតែពាក្យប៉ុណ្ណោះថា ខ្ញុំជាមិត្តរបស់អ្នក ។ បទថា* **សេយ្យានិ កម្មានិ** *សេចក្ដីថា កម្មដ៏ប្រសើរទាំងឡាយដែលមានសភាពយ៉ាងនោះរបស់ពាក្យនេះថា ខ្ញុំនឹងឲ្យ ខ្ញុំនឹងធ្វើ ។ បទថា* **អនាទិយន្តំ** *សេចក្ដីថា មិនធ្វើ ។ បទថា* **នេសោ មមំ** *សេចក្ដីថា គប្បីស្គាល់បុគ្គលបែបនេះថា អ្នកនុ៎ះ មិនមែនជាមិត្ត របស់អញ ។*

*បទថា* **បាមោជ្ជករណំ ឋានំ** *សេចក្ដីថា សូម្បីទាន សីល ភាវនា និង ភាពជាមិត្រមួយអន្លើដោយកល្យាណមិត្រដែលជាបណ្ឌិត ។ ចំណែកក្នុងទីនេះ លោកពោលសំដៅយកភាពជាមិត្រដូចប្រការដែលពោលហើយប៉ុណ្ណោះ ។ ពិតហើយ មិត្តភាពមួយអន្លើដោយកល្យាណមិត្តដែលជាបណ្ឌិត រមែងធ្វើបាមោជ្ជៈ (សេចក្ដីរីករាយទន់) និង នាំមកនូវសេចក្ដីសរសើរ ។ លោកពោលថា សេចក្ដីសុខ ព្រោះជាហេតុនៃសេចក្ដីសុខផ្លូវកាយ និងសេចក្ដីសុខផ្លូវចិត្ត ក្នុងលោកនេះ និងលោកខាងមុខ ព្រោះហេតុនោះ កុលបុត្រដែលឃើញផល និងអានិសង្សនោះ ឈ្មោះថា ជាអ្នកមានផលានិសង្ស កាលនាំមកនូវធុរៈដែលជារបស់បុរសទាំង ៤ ប្រការ ពោលគឺ ទាន សីល ភាវនា និងមិត្តភាព ដែលបុរសទាំងឡាយគប្បីនាំមក រមែងញ៉ាំងហេតុជាគ្រឿងធ្វើបាមោជ្ជ ពោលគឺមិត្តភាពនោះ និងសេចក្ដីសុខដែលនាំមកនូវសេចក្ដីសរសើរឲ្យកើត និងចម្រើនឡើង លោកសម្ដែងថា មិនទម្លាយមិត្តភាពពីបណ្ឌិត ។*

បទថា **បវិវេការសំ** សេចក្ដីថា រសនៃកាយវិវេក ចិត្តវិវេក ឧបធិវិវេក គឺរសនៃសោមនស្សដែលកើតដោយអាស្រ័យវិវេកទាំងនោះ ។ បទថា **ឧបសមស្ស ច** សេចក្ដីថា សោមនស្សដែលបានដោយកិលេសូបសមៈ (ការស្ងប់រម្ងាប់កិលេស) ។ បទថា **និទ្ទរោ ហោតិ និប្បាបោ** សេចក្ដីថា ឈ្មោះថា ជាអ្នកមិនមានកង្វល់ ព្រោះភាពជាអ្នកមិនកង្វល់ដោយកិលេសទាំងពួង ឈ្មោះថា មិនមានបាប ព្រោះភាពជាអ្នកមិនមានកិលេស ។ បទថា **ធម្មប្បីតិរសំ** សេចក្ដីថា រសពោលគឺធម្មបីតិ អធិប្បាយថា ផឹកនូវវិមុត្តិបីតិ ។

ព្រះមហាសត្វសង្វេគ តក់ស្លុតនឹងការមានបាបមិត្រហើយ កាន់យកកំពូលនៃទេសនាឲ្យបន្ទុះអមតមហានិព្វាន ដោយរសនៃវិវេក ដោយប្រការដូច្នេះឯង ។

ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

**តទា បច្ចន្តវាសី ឥទានិ បច្ចន្តវាសីយេវ** បច្ចន្តវាសិសេដ្ឋីក្នុងកាលនោះបានមកជាបច្ចន្តវាសិសេដ្ឋីក្នុងកាលឥឡូវនេះ ។

**តទា ពារាណសិសេដ្ឋិ អហមេវ អហោសិំ** ចំណែកពារាណសិវាសិសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។

ហិរិជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត វណ្ណារោហវគ្គ បិដកលេខ ៥៩ ទំព័រ ១៨)

ដោយខេមរ អភិធម្មាវតារ

ព.ស. ២៥៦១